# សេចក្តីថ្លែងការណ៍រួម
# ស្តីពី
# ការការពារ និងលើកកំពស់សិទ្ធិពលករទេសន្តរប្រវេសន៍ស្ត្រីកម្ពុជា

*ភ្នំពេញ ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ ២០១០*

យើងខ្ញុំជាតំណាងឱ្យអង្គការមិនមែនរដ្ឋាភិបាល ដែលមានសមាសភាពជាង ២០ អង្គការ-សមាគម ធ្វើការលើវិស័យទេសន្តរប្រវេសន៍ សិទ្ធិមនុស្ស ស្ត្រី និងកុមារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា សូមសំដែងនូវការអបអរសាទរចំពោះរាជរដ្ឋាភិបាលកម្ពុជា និងសមាគមអាស៊ាន ដែលបានធ្វើការអនុម័តទៅលើសេចក្តីប្រកាសអាស៊ានស្តីពីការការពារ និងការលើកកំពស់សិទ្ធិពលករទេសន្តរប្រវេសន៍ដែលត្រូវបានអនុម័តដោយប្រមុខរដ្ឋអាស៊ានកាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៧ នៅទីក្រុងសេប៊ូ ប្រទេសហ្វីលីពីន ព្រមទាំងបានបង្កើតគណៈកម្មាធិការអាស៊ានស្តីពីពលករទេសន្តរប្រវេសន៍ ដើម្បីបង្កើតលិខិតុបករណ៍អាស៊ានសំរាប់អនុវត្តសេចក្តីប្រកាសអាស៊ាននេះ។ ក្រុមអង្គការសង្គមស៊ីវិលកម្ពុជា ក៏សូមកោតសរសើរផងដែរដល់រាជរដ្ឋាភិបាលកម្ពុជា ដែលបានយកចិត្តទុកដាក់ក្នុងការការពារ និងលើកកំពស់សិទ្ធិពលករទេសន្តរប្រវេសន៍ ការបង្កើតគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ ក្រុមការងារអន្តរក្រសួងស្តីពីទេសន្តរប្រវេសន៍ និង ការដំណើរការរៀបចំធ្វើវិសោធនកម្មអនុក្រឹតលេខ ៥៧ ស្តីពីការបញ្ជូនពលករកម្ពុជាទៅធ្វើការងារនៅក្រៅប្រទេស ជាពិសេសការបង្ក្រាបទៅលើក្រុមហ៊ុនជ្រើសរើសពលករ ដែលបានបង្ខាំងមនុស្សដោយខុសច្បាប់នាពេលថ្មីៗកន្លងទៅនេះ។

ទោះបីយ៉ាងណាក៏ដោយ អង្គការសង្គមស៊ីវិលដែលធ្វើការទៅលើវិស័យពលករទេសន្តរប្រវេសន៍ សិទ្ធិមនុស្ស ស្ត្រី និងកុមារ នៅតែមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការបន្តកើតមានការរំលោភបំពាននានា ទៅលើពលករទេសន្តរប្រវេសន៍ ជាពិសេស ស្ត្រី ទាំងនៅមុនពេលចេញដំណើរ ក្រោយពេលទៅដល់ និងសមាហរណកម្ម ដូចជា ការក្លែងលិខិតសាធារណៈ ការបង្ខាំងមនុស្សដោយខុសច្បាប់ ការធ្វើអោយជាប់បំណុលក្រុមហ៊ុនជ្រើសរើសពលករ ការធ្វើកិច្ចសន្យាការងារដែលមិនមានលក្ខណៈច្បាស់លាស់ និងទុច្ចរិត ឬ កិច្ចសន្យាដែលមិនមានបទដ្ឋានអាចអនុវត្តបាននៅប្រទេសទទួល, កង្វះព័តិមានស្តីពីទេសន្តប្រវេសន៍ប្រកបដោយសុវត្ថិភាព ការធ្វើតេស្តឈាមដោយបង្ខំរកមេរោគអេដស៍ ការរើសអើងចំពោះស្ត្រីមានផ្ទៃពោះ ការកាត់ប្រាក់បៀវត្សដោយមិនមានហេតុផលសមរម្យ លក្ខខ័ណ្ឌការងារធ្ងន់ធ្ងរ (ការធ្វើការងារលើសម៉ោងមិនមានថ្ងៃឈប់សំរាក ...) មិនមានការធានារ៉ាប់រងផ្នែកសុខភាពនិងការងារ ការបំបិទសិទ្ធិសេរីភាព កង្វះការទទួលបានជំនួយផ្លូវច្បាប់ និងសេវាសង្គមផ្សេងៗ ការដកយកលិខិតឆ្លងដែន និងឯកសារគតិយុត្តិផ្សេងៗ ឧបសគ្គភាសា អំពើហិង្សា និងទំរង់នៃការរើសអើងផ្សេងៗ ។ល។

ហេតុដូច្នេះហើយ ឆ្លៀតក្នុងឱកាសដែលវេទិកាប្រជាជនអាស៊ាន នឹងប្រព្រឹត្តធ្វើនៅថ្ងៃទី ២៤ ដល់ ២៦ ខែកញ្ញា ឆ្នាំ២០១០ នៅទីក្រុងហាណូយ ប្រទេសវៀតណាម យើងខ្ញុំជាក្រុមអង្គការសង្គមស៊ីវិល សូមលើកជូនអនុសាសន៍មួយចំនួនសំរាប់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាប្រមុខមេដឹកនាំអាស៊ានដូចតទៅៈ

**អនុសាសន៍ជូនចំពោះរាជរដ្ឋាភិបាលកម្ពុជា**

១- ពន្លឿនដំណើរការធ្វើវិសោធនកម្មអនុក្រឹតលេខ៥៧ ស្តីពីការបញ្ជូនពលករទេសន្តប្រវេសន៍ទៅក្រៅប្រទេសដោយធ្វើកិច្ចពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល និងអនុវត្តគោលនយោបាយទេសន្តប្រវេសន៍អោយមាន ប្រសិទ្ធិភាព ។

២- ចរចាជាមួយរដ្ឋាភិបាលប្រទេសទទួល ដើម្បីបង្កើតឱ្យបានកិច្ចសន្យាបទដ្ឋានមួយអាចអនុវត្តបាននៅប្រទេសទទួល ដោយមានចែងអំពីលក្ខខណ្ឌការងារច្បាស់លាស់ (ដូចជាៈ ថ្ងៃឈប់សំរាក ការឈប់សំរាកមាតុភាព ការឈប់សំរាកប្រចាំឆ្នាំ ។ល។) ហើយធានានូវសិទ្ធិការងារជាមូលដ្ឋាន ជាពិសេស ការងារបំរើតាមផ្ទះត្រូវបានដាក់បញ្ចូលនៅក្នុងច្បាប់ការងារ ។

៣- លុបបំបាត់ការបង្ខំអោយធ្វើតេស្តឈាមរកមេរោគអេដស៍ និងការមានផ្ទៃពោះ ។

៤- រឹតបន្តឹងយន្តការត្រួតពិនិត្យទៅលើគោលនយោបាយ កិច្ចសន្យាការងារ និងនីតិវិធីនានាក្នុងការជ្រើសរើសរបស់ក្រុមហ៊ុន ឬ ភ្នាក់ងារជ្រើសរើសពលករទេសន្តប្រវេសន៍កម្ពុជាអោយធ្វើការនៅក្រៅប្រទេស ដោយកំណត់ឱ្យបានច្បាស់លាស់នូវកាតព្វកិច្ច និងការទទួលខុសត្រូវរបស់ភ្នាក់ងារជ្រើសរើសទាំងនោះ ដែលចាំបាច់ត្រូវតែទទួលស្គាល់ជាផ្លូវការដោយរាជរដ្ឋាភិបាលកម្ពុជា ជាពិសេស ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មុននឹងអនុញ្ញាតឱ្យដំណើរការសកម្មភាពផ្សេងៗ ។

៥- កំណត់គោលការណ៍អំពីការកំណត់ថ្លៃសមរម្យក្នុងការរៀបចំឯកសារសំរាប់ការចេញដំណើរទៅធ្វើការនៅប្រទេសទទួល ។

៦- ជំរុញនិងបង្កើតការវិនិយោគនៅក្នុងស្រុកអោយបានច្រើន ជាពិសេសបង្កើតកាងារក្នុងស្រុកសំរាប់ស្ត្រី ដើម្បីកាត់បន្ថយការធ្វើទេសន្តរប្រវេសន៍ និងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។

៧- ផ្តល់វគ្គបណ្តុះបណ្តាលមុនពេលចេញដំណើរដល់ពលករ ជាពិសេសស្ត្រី អំពីសិទ្ធិការងារជាមូលដ្ឋាន និងព័ត៌មានអំពីការធ្វើទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាពដោយសហការជាមួយសង្គមស៊ីវិល និងស្ថាប័នពាក់ព័ន្ធ ។

៨- ផ្តន្ទាទោសឱ្យបានពិតប្រាកដភ្នាក់ងារជ្រើសរើសពលករទេសន្តប្រវេសន៍ណាដែលបង្ករបទល្មើសព្រហ្មទណ្ឌ ដូចជាៈ ការឃុំឃាំងបំបិទសិទ្ធិសេរីភាព ការបង្ករបួសស្នាម ការរំលោភបំពានលើរូបរាងកាយ និងផ្លូវភេទលើស្ត្រី ។

៩- បង្កើតសេនានុព័ន្ធការងារនៅតាមស្ថានទូតរបស់កម្ពុជាប្រចាំប្រទេសទទួល និងបណ្តុះបណ្តាលមន្ត្រីសេនានុព័ន្ធការងារ និងមន្ត្រីរដ្ឋាភិបាលនានាអំពីបញ្ហាទេសន្តប្រវេសន៍ និងយេនឌ័រ ដើម្បីការពារ និងលើកកំពស់សិទ្ធិពលករទេសន្តរប្រវេសន៍ជាស្ត្រី ។



ខ្

**អនុសាសន៍ចំពោះសមាគមអាស៊ាន និងរដ្ឋសមាជិកអាស៊ាន**

១- បំពេញកាតព្វកិច្ចអោយបានពេញលេញក្នុងការចាត់វិធានការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងស្ត្រីភេទ ហើយបង្កើតច្បាប់ជាតិ និងគោលនយោបាយអោយស្របទៅតាមអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់នូវរាល់ទំរង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ និងអនុសាសន៍ទូទៅលេខ២៦ នៃអនុសញ្ញានេះ ដោយសារបណ្តាប្រទេសអាស៊ានទាំងអស់ បានផ្តល់សច្ចាប័នទៅលើអនុសញ្ញានេះ ។

២- បង្កើតលិខិតុបករណ៍ក្របខណ្ឌអាស៊ានដែលមានលក្ខណៈគតិយុត្តិ ដើម្បីការពារ និងលើកកំពស់សិទ្ធិពលករទេសន្តរប្រវេសន៍ ជាពិសេស ស្ត្រីដែលធ្វើការងារនៅតាមវិស័យផ្សេងដូចជា ការងារតាមផ្ទះ និងវិស័យការងារក្រៅប្រព័ន្ធផ្សេងៗ ។ល ។ ដោយមិនគិតពីប្រភេទការងាររបស់គេឡើយ ។

៣- ជំរុញការអនុវត្តឱ្យមានប្រសិទ្ធិភាព និងឱ្យបានពេញលេញនូវគណៈកម្មាធិការនានា ដែលត្រូវបានបង្កើតឡើងនៅក្នុងក្របខណ្ឌអាស៊ាន ជាពិសេស គណៈកម្មាធិការអាស៊ានស្តីពី ពលករទេសន្តប្រវេសន៍ និងគណៈកម្មាធិការអាស៊ាន ដើម្បីលើកស្ទួយ និងការពារសិទ្ធិស្ត្រី និងកុមារ ។

៤- បង្កើតយន្តការដើម្បីទទួល និងដោះស្រាយពាក្យបណ្តឹងពលលករទេសន្តប្រវេសន៍ ដែលធ្វើការនៅក្នុង តំបន់អាស៊ាន ជាពិសេសនៅខណៈពេលដែលសមាហរណកម្មសេដ្ឋកិច្ចកាន់តែខិតជិតមកដល់នៅឆ្នាំ២០១៥ ខាងមុខនេះ ។

៥- ពិចារណាក្នុងការបង្កើតឱ្យមាននូវកិច្ចព្រមព្រៀងស្តីពី "*កញ្ចប់ធានារ៉ាប់រងសេវាសុខភាពជាស្តង់ដារ*" មួយ ដែលនឹងត្រូវផ្តល់ដោយប្រទេសទទួល (ដោយសហការជាមួយប្រទេសបញ្ជូន) ដើម្បីជួយធានារ៉ាប់រងសុខភាពរបស់ពលករក្នុងពេលបំពេញការងារនៅប្រទេសទទួល ជាពិសេសសំរាប់ស្ត្រីភេទ នូវសេវាសុខភាពសាធារណៈដូចជាៈ សេវាបង្ការ ព្យាបាល និងសេវាពិនិត្យសុខភាពបន្តពូជ និងការមានផ្ទៃពោះ ជាដើម ។

៦- បញ្ឈប់ការដកហូតលិខិតឆ្លងដែន ឬឯកសារសំគាល់ខ្លួនជាផ្លូវការរបស់ពលករទេសនប្រវេសន៍ស្របច្បាប់ពីសំណាក់ក្រុមហ៊ុនឯកជន ឬអ្នកទទួល នៃប្រទេសទទួល ។ តែ បើត្រូវដកហូត អាជ្ញាធរត្រូវចេញប័ណ្ណ ឬឯកសារផ្លូវការសំរាប់សំគាល់ខ្លួនក្នុងការធ្វើដំណើររបស់គេដោយពេញលេញ និងដោយមិនមានការរំខាន ។

----------------

*សំរាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង*


១. **លោក យ៉ា ណារ៉ុថ** នាយកប្រតិបត្តិអង្គការខារ៉ាមកម្ពុជា (CARAM Cambodia) ០១២ ៩៦១ ៤២៧

២. **លោក សួន សារ៉េត** លេខាធិការដ្ឋានប្រតិបត្តិគណកម្មាធិការប្រព្រឹត្តិកម្ម (CHRAC) ០៩២ ៣៤៤ ៣៥៧

៣. **លោក ហង្ស ពុទ្ធា** អគ្គលេខាធិការនៃ NGOCEDAW ០១២ ៩៥៩ ៦៦៦

*ខាងក្រោមនេះ គឺបញ្ជីឈ្មោះក្រុមអង្គការសង្គមស៊ីវិល ដែលគាំទ្រសេចក្តីថ្លែងការណ៍នេះ*

| ល.រ | ឈ្មោះស្ថាប័នជាភាសាឡាតាំង |
|---|---|
| ១ | Coordination of Action Research on AIDS and Mobility (CARAM Cambodia) |
| ២ | Coordination of Action Research on AIDS and Mobility (CARAM Asia) |
| ៣ | APLWD |
| ៤ | Positive for Change in Cambodia (PCC) |
| ៥ | Phnom Srey Association Development (PSAD) |
| ៦ | Banteay Srey |
| ៧ | Women Development Association (WDA) |
| ៨ | SILAKA |
| ៩ | HCC |
| ១០ | NGOCEDAW |
| ១១ | Voice of Democracy (VoD) |
| ១២ | Women Media Center (WMC) |
| ១៣ | LICADHO |
| ១៤ | Cambodia Women Development Agency (CWDA) |
| ១៥ | Cambodia Women Crisis Centre (CWCC) |
| ១៦ | Caritas |
| ១៧ | Cambodia Human Rights Action Committee (CHRAC) |
| ១៨ | SACRED |
| ១៩ | Cambodia Centre for Human Rights (CCHR) |
| ២០ | Legal Support for Children and Women (LSCW) |
| ២១ | ADHOC |